▶クリックで音声再生▶

ភាសាខ្មែរ
クメール語

# まんがでわかる
# 交通労働災害の防止

ស្វែងយល់តាមរយៈគំនូរត្លុកម៉ាំងហ្គា
## ការបង្ការគ្រោះថ្នាក់ការងារ ពាក់ព័ន្ធចរាចរណ៍

ឯកសារសិក្សាសម្រាប់មើលនិងស្តាប់នេះ ត្រូវបានបង្កើតឡើងក្នុងគោលបំណងសម្រាប់ការសិក្សាពីមូលដ្ឋាននៃក្បួនច្បាប់ និងសុវត្ថិភាពដើម្បីបង្ការគ្រោះថ្នាក់ការងារពាក់ព័ន្ធចរាចរណ៍សម្រាប់លោកអ្នកដែលជានិយោជិត។



| | | |
|---|---|---|
| 1 | ពាណិជ្ជកម្ម | 1672 |
| 2 | ទូរគមនាគមន៍ | 866 |
| 3 | វិស័យដឹកជញ្ជូនទំនិញផ្លូវគោក | 792 |
| 4 | អាជីវកម្មគមនាគមន៍ | 740 |
| 5 | វិស័យសុខាភិបាលនិងអនាម័យ | 612 |
| 6 | វិស័យសំណង់ | 542 |

ក្រសួងសុខាភិបាលការងារនិងសុខុមាលភាព "ស្ថានភាពនៃ
ការកើតឡើងនៃគ្រោះថ្នាក់ការងារ (ឆ្នាំ2020)"

ត្រូវហើយ។
មិនថាវិស័យណាទេ ចំណុចរួមក្នុងគ្រោះថ្នាក់ការងារពាក់ព័ន្ធចរាចរណ៍ជាច្រើនគឺការជួបគ្រោះថ្នាក់ចរាចរណ៍ពេលធ្វើដំណើរទៅមកកន្លែងធ្វើការដោយដើរឬជិះកង់។
ជាពិសេស កង់មិនត្រឹមតែអាចក្លាយជាជនរងគ្រោះប៉ុណ្ណោះទេ គឺក៏អាចក្លាយជាអ្នកបង្កគ្រោះថ្នាក់ផងដែរ។
តើគ្រោះថ្នាក់ក្នុងពេលធ្វើដំណើរទៅមកកន្លែងធ្វើការក៏ជាគ្រោះថ្នាក់ការងារដែរឬ?
វាជាគ្រោះថ្នាក់ការងារ... ហើយពេលបើកឡានទៅទីតាំងអតិថិជនឬទីតាំងការងារផ្ទាល់ក៏កើតមានគ្រោះថ្នាក់ច្រើនដែរ។

អ៊ីចឹងធ្វើម៉េចដើម្បីការពារគ្រោះថ្នាក់ការងារពាក់ព័ន្ធចរាចរណ៍ទៅ?
ប្រាកដណាស់សាមីខ្លួនត្រូវប្រុងប្រយ័ត្ន ហើយសំខាន់គឺគោរពតាមច្បាប់ចរាចរណ៍ដែលបានកំណត់។
ហ៊ឹម...
សំខាន់ឲ្យតែប្រយ័ត្ននឹងឡាននៅជុំវិញទៅគឺបានហើយ មិនអ៊ីចឹង?
ថាម៉េច?
ទោះបីវាមិនស្រួលក៏ដោយតែវាគឺសំខាន់ដើម្បីការពារខ្លួនឯងនិងអ្នកជុំវិញកុំឲ្យរងរបួស!
បាទ...!

ម្យ៉ាងទៀត នៅក្នុងវិស័យដែលប្រើរថយន្តពេលធ្វើការងារដូចជា "វិស័យដឹកជញ្ជូនទំនិញផ្លូវគោក" "វិស័យគមនាគមន៍" "វិស័យសំណង់" ក៏កំពុងកើតមានឡើងនូវគ្រោះថ្នាក់នៅកន្លែងការងារផ្ទាល់ដូចជាពេលកំពុងផ្ទុកទំនិញ ពេលកំពុងឲ្យសញ្ញានាំផ្លូវចរាចរណ៍ជាដើម។
មិនមែនត្រឹមតែអ្នកបើកបរបង្កគ្រោះថ្នាក់ប៉ុណ្ណោះទេ ករណីដែលអ្នកធ្វើការនៅក្បែរឡានដឹកទំនិញជាដើមត្រូវបានឡានដឹកទំនិញកិន ក៏មានច្រើនដែរ។
បើរងរបួសធ្វើការមិនបាន គ្រួសារខ្ញុំក៏នឹងព្រួយបារម្ភ ហើយខាងប្រាក់ចំណូលក៏នឹងជួបបញ្ហាដែរ...។
អ៊ីចឹងហើយបានជាការត្រៀមខ្លួនជានិច្ចគឺសំខាន់។
ជាពិសេសឡានធំៗមានជ្រុងមើលមិនឃើញធំ អ៊ីចឹងទោះបីមានមនុស្សនៅក្បែរក៏ពិបាកនឹងចាប់អារម្មណ៍ដែរ។ វាសំខាន់ដែលអ្នកធ្វើការនៅក្បែរក៏ត្រូវដឹងពីជ្រុងមើលមិនឃើញរបស់ឡានធំៗដែរ។
ម្យ៉ាងទៀត ទោះបីប្រញាប់ក៏ដោយ វាក៏សំខាន់ផងដែរដែលត្រូវស្ងប់អារម្មណ៍ពិនិត្យមើលសុវត្ថិភាពរួចសឹមធ្វើអ្វីមួយ។

បើនិយាយឲ្យជាក់លាក់ទៅ តើមានករណីបែបណាខ្លះទៅ?
មានករណីជាក់ស្ដែងគឺពេលដើរកាត់ចំពីក្រោយឡានដឹកទំនិញដែលកំពុងឈប់ ឡានដឹកទំនិញស្រាប់តែបើកថយក្រោយភ្លាមៗហើយបានកៀរ។
ពីកៅអីអ្នកបើកមកគឺមើលអ្នកធ្វើការមិនឃើញហើយក៏បណ្ដាលឲ្យមានគ្រោះថ្នាក់។
គួរឱ្យខ្លាច...។
ដើម្បីកុំឱ្យជួបគ្រោះថ្នាក់ការងារពាក់ព័ន្ធចរាចរណ៍បែបនេះ
ដំបូងគោះយើងមើលអំពីចំណេះដឹងមូលដ្ឋានដើម្បីបង្ការគ្រោះថ្នាក់!
បាទ/ចាស!

ប្រការប្រុងប្រយ័ត្ន ពេលធ្វើដំណើរទៅមកកន្លែងធ្វើការ(ដើរ)
ពេលធ្វើដំណើរទៅមកកន្លែងធ្វើការក៏មានគ្រោះថ្នាក់ដែរ។
សូមគោរពច្បាប់ចរាចរណ៍ទាំងអស់គ្នាដើម្បីកាត់បន្ថយគ្រោះថ្នាក់។
កុំឆ្លងកាត់នៅកន្លែងដែលគ្មានគំនូសថ្មើរជើងឆ្លងកាត់។
ពិនិត្យឆ្វេងស្តាំរួចសឹមឆ្លងកាត់លើគំនូសថ្មើរជើងឆ្លងកាត់។
ករណីគំនូសថ្មើរជើងឆ្លងកាត់ដែលគ្មានភ្លើងស្តុប ត្រូវបង្ហាញពីបំណងចង់ឆ្លងកាត់ឲ្យច្បាស់លាស់ដោយលើកដៃជាដើម។
កុំឆ្លងកាត់ផ្លូវថ្នល់ តាមទិសបញ្ឆិត។

គោរពភ្លើងស្តុប។
កុំស្ទុះចេញភ្លាមៗទៅផ្លូវយានជំនិះ។
ប្រយ័ត្ននឹងគ្រោះថ្នាក់កើតមាននៅផ្លូវបំបែក។
នៅជប៉ុន ឡានបើកបរប្រកាន់ឆ្វេង ដូច្នេះចាំបាច់ត្រូវប្រយ័ត្ននឹងឡានបត់ឆ្វេងជាពិសេស។
ជាពិសេសឡានធំៗដូចជាឡានដឹកទំនិញជាដើម សូមប្រយ័ត្ននឹងចន្លោះត្រូវការដើម្បីបត់។
ចន្លោះត្រូវការដើម្បីបត់?
ពេលឡានបត់ កង់ក្រោយនឹងបរកាត់ចូលផ្នែកខាងក្នុងជាងទីតាំងដែលកង់មុខបរកាត់ទៅទៀត។ គេហៅវាថា "ចន្លោះត្រូវការដើម្បីបត់"។
អំពីចន្លោះត្រូវការដើម្បីបត់ក៏មានពន្យល់លម្អិតក្នុង "ប្រការប្រុងប្រយ័ត្ននៅទីតាំងការងារផ្ទាល់" ដែរ។

# ក្បួនច្បាប់សុវត្ថិភាពពេលជិះកង់




* កង់គឺជាយានជំនិះ 1 ប្រភេទហើយក្រៅពីនេះក៏មានក្បួនច្បាប់ផ្សេងៗផងដែរ។

គន្លឹះជិះកង់
ដោយសុវត្ថិភាព
តោះយើងមើលគន្លឹះនៃការជិះកង់។
ប្រយ័ត្នកុំជិះលឿនជ្រុលពេលចុះជម្រាល។
នៅជប៉ុន មានជម្រាលច្រើន ដូច្នេះត្រូវប្រយ័ត្ន!
ប្រយ័ត្នរអិលនឹងគម្របលូ ពេលមេឃភ្លៀង។
គម្របលូពេលមេឃភ្លៀង គឺរអិលមែន។


ការត្រួតពិនិត្យកង់ជាទៀងទាត់
លើសពីនេះ ការត្រួតពិនិត្យកង់ជាទៀងទាត់នឹងធ្វើឲ្យយើងទុកចិត្តបាន។
ដៃកង់ តើបានរឹតតឹងជាប់កែងគ្នានឹងកង់មុខឬទេ?
ប្រាំង ទាំងមុខទាំងក្រោយប្រាំងស៊ីទេ?
កែបកង់ មានរលុងទេ ហើយកម្ពស់ដាក់ជើងទាំងសងខាងដល់ដីទេ?
ផ្ទាំងចាំងពន្លឺ មានជាប់ទេ កខ្វក់ទេ មើលឃើញច្បាស់ទេ?
ចង្កៀងមុខ(អំពូល) តើបើកភ្លឺទេ?
ច្រវាក់ យារពេកទេ?
កង់ តើតឹងល្អគ្រប់គ្រាន់ទេ ផ្ទៃសំបកកង់មានសឹកទេ?
ឈ្នាន់ មានកោងជាដើម ធ្វើឲ្យជើងរអិលទេ?
គ្រឿងបន្លាស់ផ្សេងទៀត ភ្ជាប់ជាប់ត្រឹមត្រូវទេ?
ចំពោះកង់ ក្រៅពីនេះមានអ្វីដែលត្រូវប្រយ័ត្នទៀតទេ?
ហ៊ឹម...
ថ្មីៗនេះ គ្រោះថ្នាក់ដែលបណ្តាលមកពេលកំពុងដឹកជញ្ជូនដោយកង់ កំពុងតែកើនឡើង។
អូ...
បែបតក់ក្រហល់ដោយសារគិតថាត្រូវឆាប់ដឹកឲ្យលឿនហើយមើលទៅ។
តក់ក្រហល់គឺជាដើមហេតុនៃគ្រោះថ្នាក់។
ទោះរវល់ក៏ដោយ វាសំខាន់ដែលត្រូវត្រួតពិនិត្យសុវត្ថិភាពឲ្យបានត្រឹមត្រូវ។

# ប្រការប្រុងប្រយ័ត្នពេលធ្វើដំណើរទៅមកកន្លែងធ្វើការ (ឡាន ម៉ូតូ)

## ប័ណ្ណបើកបរដែលអាចបើកបរបានក្នុងប្រទេសជប៉ុន

| | |
|---|---|
| • ប័ណ្ណបើកបរជប៉ុន<br> <br>* រួមទាំងករណីដែលប្តូរប័ណ្ណបើកបរដែលទទួលបាននៅបរទេសទៅជាប័ណ្ណបើកបរជប៉ុន។ | • ប័ណ្ណបើកបរអន្តរជាតិផ្អែកលើអនុសញ្ញាទីក្រុងហ្សឺណែវ<br>• ប័ណ្ណបើកបរបរទេស (មានភ្ជាប់ការបកប្រែជាភាសាជប៉ុន)<br>* បច្ចុប្បន្នគឺសម្រាប់តែប្រទេសស្វីស អាល្លឺម៉ង់ បារាំង បែលហ្ស៊ិក ម៉ូណាកូ និង តៃវ៉ាន់ប៉ុណ្ណោះ។ |
| រយៈពេលអាចបើកបរនៅជប៉ុន<br>ក្នុងកំលុងពេលមានសុពលភាព។ | រយៈពេលអាចបើកបរនៅជប៉ុន<br>រយៈពេលដែលខ្លីជាងក្នុងចំណោម រយៈពេលមួយឆ្នាំគិតពីថ្ងៃចូលដល់ប្រទេសជប៉ុន ឬរយៈពេលសុពលភាពនៃប័ណ្ណបើកបរ។ |

## ច្បាប់ចរាចរណ៍ជប៉ុន

នៅគំនូសថ្មើរជើងឆ្លងកាត់ ត្រូវផ្តល់អាទិភាពដល់អ្នកថ្មើរជើង។



ពេលភ្លើងក្រហម ហាមធ្វើដំណើរទៅមុខ។



បើកបរប្រកាន់ឆ្វេង។



គន្លឹះក្នុងការបើកបររថយន្តម៉ូតូដោយសុវត្ថិភាព
តោះយើងមើលចំណុចដែលចង់ឲ្យប្រយ័ត្នក្រៅពីនេះ
ដើម្បីបង្ការគ្រោះថ្នាក់កុំឲ្យកើតឡើង។
ការពិនិត្យសុវត្ថិភាព មិនត្រឹមតែខាងមុខប៉ុណ្ណោះទេ គឺទាំងខាងក្រោយនិងឆ្វេងស្តាំផងដែរ!
ធ្វើយ៉ាងណាកុំឲ្យខកខានការប្រាស្រ័យទាក់ទងពេលបើកបរ!
ពេលបើកបរក្នុងអាកាសធាតុមិនល្អ ត្រូវប្រយ័ត្នរអិលជាដើម!
ប្រយ័ត្នភ្លៀង ព្រិល ត្រជាក់កក អ័ព្ទ ខ្យល់ខ្លាំងជាដើម។
នៅតំបន់លំនៅដ្ឋានឬផ្លូវតូចចង្អៀត ត្រូវបើកបរយឺតៗដោយគិតដល់អ្នកថ្មើរជើងនិងកង់!
ត្រូវបើកបរដោយសុវត្ថិភាពកុំឲ្យក្លាយជាអ្នកបង្កគ្រោះថ្នាក់
នៅពេលអ្នកក្លាយជាអ្នកបង្កគ្រោះថ្នាក់...
អីយ៉ូយ... អត់ចង់ដាច់ខាត...
ទោសព្រហ្មទណ្ឌ
អាចនឹងត្រូវសងការខូចខាត ជាប់ទោសព្រហ្មទណ្ឌដូចជាពិន័យជាប្រាក់និងជាប់ពន្ធនាគារជាដើម។
ពិន័យឬបញ្ឈប់ពីការងារ
អាស្រ័យលើបទប្បញ្ញត្តិរបស់ក្រុមហ៊ុន ក៏អាចនឹងរងពិន័យឬបញ្ឈប់ពីការងារផងដែរ។
ផលប៉ះពាល់ផ្នែកសង្គម
NEWS
ក៏អាចត្រូវបានចុះផ្សាយដោយប្រើឈ្មោះពិតក្នុងទូរទស្សន៍ផងដែរ។ ជាពិសេសការបើកបរដោយពិសាគ្រឿងស្រវឹងត្រូវបានចាប់អារម្មណ៍ខ្លាំងក្នុងសង្គម។




ប្រការប្រុងប្រយ័ត្ននៅទីតាំងការងារផ្ទាល់
នៅទីតាំងការងារផ្ទាល់ ការប្រុងប្រយ័ត្ននឹងឡានដឹកទំនិញដែលនៅជុំវិញ ក៏សំខាន់ខ្លាំងដែរ។
ឡានធំៗដូចជាឡានដឹកទំនិញជាដើម មានជ្រុងមើលមិនឃើញច្រើន។ នៅពេលឲ្យសញ្ញានាំផ្លូវចរាចរណ៍ឬនៅការដ្ឋានសំណង់ជាដើម សូមប្រយ័ត្នកុំនៅជ្រុងមើលមិនឃើញ។
ជ្រុងមើលមិនឃើញរបស់ឡានដឹកទំនិញ
ផ្នែកខាងក្រោយបញ្ចិតខាងស្តាំ ផ្នែកខាងក្រោយបញ្ចិតខាងឆ្វេងរបស់អ្នកបើកបរ គឺងាយនឹងក្លាយជាជ្រុងមើលមិនឃើញ។
ផ្នែកខាងក្រោយឡានគឺជាជ្រុងមើលមិនឃើញសោះតែម្តង។
ចំពោះឡានកម្ពស់ខ្ពស់ កន្លែងនៅកៀកខាងមុខអ្នកបើកបរគឺជាជ្រុងមើលមិនឃើញ។
ចន្លោះត្រូវការដើម្បីបត់របស់ឡានដឹកទំនិញ
ពេលឡានបត់ កង់ក្រោយនឹងបរកាត់ចូលផ្នែខាងក្នុងជាងទីតាំងដែលកង់មុខបរកាត់ទៅទៀត។ គេហៅវាថា "ចន្លោះត្រូវការដើម្បីបត់"។
ជាពិសេសចំពោះឡានធំ ចន្លោះត្រូវការដើម្បីបត់គឺកាន់តែធំ។
ទោះបីគិតថានៅឆ្ងាយគ្រប់គ្រាន់ហើយក៏ដោយ ក៏អាចគ្រោះថ្នាក់ដែរ ហេតុនេះសូមប្រយ័ត្ន។
នៅឃ្លាតឆ្ងាយក៏រងគ្រោះថ្នាក់ដែរ!

ចំណុចសំខាន់នៃ
ការធ្វើការនៅក្បែរ
ឡានដឹកទំនិញ
ចំពោះការងារដូចជាសន្តិសុខ
រៀបចំចរាចរណ៍និងជំនួយការ
អ្នកបើកបរឡានដឹកទំនិញជាដើម
ជ្រុងមើលមិនឃើញគឺងាយនឹង
កើតមានឡើងហើយងាយនឹងកើត
មានគ្រោះថ្នាក់ដោយសារការស្ទុះ
ចេញភ្លាមៗឬខ្វះការប្រុងប្រយ័ត្ន។
តោះមើលចំណុចចង់ឲ្យប្រុងប្រយ័ត្ន
ពេលធ្វើការនៅក្បែរឡានដឹកទំនិញ!
ប្រយ័ត្ននឹងជ្រុងមើលមិនឃើញពេល
ផ្ទុកឬទម្លាក់ទំនិញឡានដឹកទំនិញ។
ប្រយ័ត្ននឹងជ្រុងមើលមិនឃើញនិងឡាន
កំពុងបើកបរក្នុងឃ្លាំង/ទីតាំងការងារ។
កុំនៅជ្រុងមើលមិនឃើញរបស់អ្នកបើកបរ។
ពេលធ្វើការងារដោយបន្ទន់ជង្គង់ចុះ អ្នកបើកបរពិបាកមើលឃើញ
ដូច្នេះអ្នកធ្វើការងារក៏ត្រូវប្រយ័ត្នដែរ។
ម្យ៉ាងទៀត ត្រូវពាក់សម្លៀកបំពាក់ជាដើមដែលលេចធ្លោ។

ប្រយ័ត្ននឹងការផ្តោតអារម្មណ៍
ភ្លេចខ្លួនពេលឲ្យសញ្ញានាំផ្លូវ។
オーライ
オーライ…
ドッ
កុំស្ទុះចេញភ្លាមៗទៅផ្លូវថ្នល់។
ビュー
ビュー
ពេលឆ្លងកាត់ក្បែររថយន្ត
ត្រូវពិនិត្យសុវត្ថិភាព។
STOP
ブウーッ
គោរពក្បួនច្បាប់នៅក្នុងឃ្លាំង/ទីតាំង។
ドッ
យល់ទេ?
តោះបន្ទាប់មកទៀតយើងមើល
ថាតើជាក់ស្តែងមានករណី
បែបណាខ្លះតាមរយៈសាច់រឿង។

# CASE 1

ថ្ងៃនេះជិតដល់ម៉ោងហើយ...!
ហ៊ឹម?
ズズン…
មេឃដូចចង់ភ្លៀង!
ឆត្រនៅណាអ៊ីចេះ!
ឲ្យតែពេលប្រញាប់គឺអ៊ីចឹងហ្មង...!
រកឃើញហើយតែដល់ម៉ោងឥឡូវហើយ!
ទាល់តែស្រូតបានបាន!

អីយ៉ាស់!?
ហេ! ម៉េចមិនជិះខាងឆ្វេង!
សុំទោស!!
ガタン
គ្រោះថ្នាក់មែន...។
ហេ ផ្លូវនេះកង់ជិះបានអត់ហ្នឹង?
ជិះតែថ្ងៃនេះគួរតែមិនអីទេ!
キョロ
キョロ
មានអ្នកដើរច្រើនតែមើលទៅអាចជ្រៀតតាមចន្លោះបាន។

អីយ៉ាស់!!
ប៊ិះ!
!?
សុំទោស!
ថ្ងៃនេះ ស៊យមែន!
ហេ ភ្លៀង?
ទីបំផុត ភ្លៀងហើយ!
តែមាន ឆត្រទេតើ!
ជិតដល់កន្លែង ធ្វើការហើយ! ទៅឲ្យលឿនសិន!


នោះ
មើលឃើញកន្លែង ធ្វើការហើយ!
ហោងវិញ មកទាន់...
ហេ!?




# ចំណុចត្រូវប្រុងប្រយ័ត្នពេលជិះកង់

## ធ្វើឲ្យសល់ពេលគ្រប់គ្រាន់!



ភាពតក់ក្រហល់នាំឲ្យជិះបែបគ្រោះថ្នាក់ ដូច្នេះ
សូមធ្វើអ្វីមួយដោយទុកឲ្យសល់ពេលគ្រប់គ្រាន់។

## កង់ត្រូវប្រកាន់ឆ្វេង!



ការគោរពទីតាំងត្រូវជិះ អាច
បង្ការគ្រោះថ្នាក់ទុកជាមុន។

## កង់ជាគោលការណ៍មិនត្រូវ ធ្វើដំណើរនៅផ្លូវថ្មើរជើងទេ!



ពេលធ្វើដំណើរនៅផ្លូវថ្មើរជើង
សូមផ្ដល់អាទិភាពដល់អ្នកថ្មើរជើង។

## កុំជិះដោយ បាំងឆត្រ!

វាគ្រោះថ្នាក់ណាស់ព្រោះឆត្របាំងភ្នែក
ឬធ្វើឲ្យបាត់បង់លំនឹងជាដើម!

## សូមពាក់មួកសុវត្ថិភាព!



56% នៃអ្នកស្លាប់ដោយគ្រោះថ្នាក់ដោយសារ
កង់គឺរងរបួសក្បាល។ (ក្នុងឆ្នាំ2020)

# CASE 2

ថ្ងៃនេះ
ក៏ហាត់ដែរ...។
ហ៊ឹម?ធ្លាក់ព្រិល!?
ជិះកង់ទៅផ្ទះវិញ
កើតអត់មើលទៅ។
តែ
អត់ចង់
ដើរ...។
ផ្លូវគ្រាន់តែសើមតែ
ដូចជាមិនកកទេ
អ៊ុចឹង
គួរតែអាច
ទៅបាន!
キコ キコ
止まれ
STOP
មានផ្លាក
សញ្ញាឲ្យឈប់...

អត់សូវមានមនុស្សទេ
មិនអីទេមើលទៅ។
អីយ៉ាស់!?
សុំទោស។
គ្រោះថ្នាក់មែន...។
ហ៊ឹម?
ងាយរអិលដោយសារ
ព្រិលទេដឹង?
ថ្ងៃធ្លាក់ព្រិលគួរឲ្យខ្លាចមែន។

មានឡាន ដឹកទំនិញ។
ធ្វើដល់យប់ ពិបាកមែន...។
អីយ៉ាស់!
ចុមយក្ស។
សុំទោស។
ពេលនឿយហត់ទៅ ធ្វើខុសកាន់តែច្រើន...។
កន្លែងនេះមានឡានច្រើន ពិបាកឆ្លងផ្លូវមែន។
គំនូសថ្មើរជើងឆ្លង កាត់ក៏នៅឆ្ងាយទៀត។
ឡានកំពុងមក តែឆ្លងទាន់មើលទៅ។
ហាស?
យីស។
ស្មានមិនដល់ថា ឡាននៅជិតសោះ...!?
ណែ!! មើលផ្លូវខាងមុខផង!!
ចង់ឲ្យឆាប់ ដល់ផ្ទះណាស់។
ជិតដល់ ផ្ទះហើយ...។
ភ្លើងស្តុបជិត ក្រហមហើយ!
ឥឡូវបើស្រួត អាចឆ្លងផុត...។

# ចំណុចត្រូវប្រុងប្រយ័ត្នពេលជិះកង់

## កុំពាក់កាសត្រចៀក!

បើពាក់កាសត្រចៀក សមត្ថភាពប្រុងប្រយ័ត្ននឹងអ្វីនៅជុំវិញខ្លួនធ្លាក់ចុះ ដូច្នេះវាមានគ្រោះថ្នាក់។

* ការជិះដោយពាក់កាសត្រចៀក ត្រូវបានហាមឃាត់ដោយរាជធានីខេត្តជាច្រើន។

## សូមគោរពផ្លាកសញ្ញា!

នៅកន្លែងដែលមានផ្លាកសញ្ញាឲ្យឈប់ សូមឈប់កុំខាន។

## ពេលយប់ ពេលអាកាសធាតុមិនល្អ នឹងទៅជាពិបាកមើល!



ពេលយប់ឬពេលអាកាសធាតុមិនល្អ វានឹងពិបាកស្មានចម្ងាយឬមើលវត្ថុជាគោលដៅ ដូច្នេះធ្វើដំណើរដោយប្រុងប្រយ័ត្ន។

## នៅគំនូសថ្មើរជើងឆ្លងកាត់ សូមចុះបណ្ដើរ!



ពេលឆ្លងកាត់ផ្នែកថ្មើរជើងនៃគំនូសថ្មើរជើងឆ្លងកាត់ សូមចុះបណ្ដើរ លើកលែងតែករណីគ្មានហានិភ័យនៃការរំខានដល់ការធ្វើដំណើររបស់អ្នកថ្មើរជើង។



## ចំណុចចង់ឲ្យប្រុងប្រយ័ត្នអំពី គ្រោះថ្នាក់ការងារពាក់ព័ន្ធចរាចរណ៍

### 1 | គោរពច្បាប់ចរាចរណ៍

សូមបញ្ឈប់ការធ្វើចរាចរណ៍បែបគ្រោះថ្នាក់ ដែលមិនគោរពច្បាប់ចរាចរណ៍។

### 2 | ប្រយ័ត្ននឹងជ្រុងមើលមិនឃើញរបស់ឡានដឹកទំនិញ



ឡានធំៗដូចជាឡានដឹកទំនិញជាដើម មានជ្រុងមើលមិនឃើញ។ សូមប្រយ័ត្ននឹងចន្លោះត្រូវការដើម្បីបត់ពេលបត់ឆ្វេងផងដែរ។

### 3 | គោរពច្បាប់ ពេលជិះកង់



ជាពិសេសសូមគោរពច្បាប់ខាងក្រោម។

- ជាទូទៅកង់សូមជិះនៅផ្លូវយានជំនិះ(ផ្លូវថ្មើរជើងគឺករណីលើកលែង)។
- នៅផ្លូវយានជំនិះ សូមប្រកាន់ឆ្វេង។
- នៅផ្លូវថ្មើរជើង សូមជិះយឺតៗនៅខាងជាប់នឹងផ្លូវយានជំនិះដោយផ្តល់អាទិភាពឲ្យអ្នកថ្មើរជើង។ សូមធ្វើយ៉ាងណាកុំឲ្យអ្នកថ្មើរជើងមានអារម្មណ៍ថាមានគ្រោះថ្នាក់។

### 4 | អាចនឹងក្លាយជាអ្នកបង្កគ្រោះថ្នាក់

កង់និងរថយន្ត ក្នុងករណីខ្លះអាចជាអ្នកបង្កគ្រោះថ្នាក់។

ដើម្បីកាត់បន្ថយផលប៉ះពាល់ ការពាក់មួកសុវត្ថិភាពសម្រាប់កង់ដែលការពារក្បាលក៏មានសារៈសំខាន់ដែរ។

ស្វែងយល់តាមរយៈគំនូរតុក្កតាម៉ាំងហ្គា

## ការបង្ការគ្រោះថ្នាក់ការងារពាក់ព័ន្ធចរាចរណ៍

ចេញផ្សាយ ខែមីនាឆ្នាំ2022

ចេញផ្សាយដោយ៖ ក្រសួងសុខាភិបាលការងារនិងសុខុមាលភាព

រៀបចំដោយ៖ Mizuho Research & Technologies, Ltd.

សហការជាមួយ៖ ការងារបង្កើតសម្ភារឧបទេសសម្រាប់ការអប់រំអំពីសុវត្ថិភាពអនាម័យពាក់ព័ន្ធនឹងគ្រោះថ្នាក់ចរាចរណ៍

ផលិតដោយ៖ Sideranch Inc.

厚生労働省
Ministry of Health, Labour and Welfare

ទំនាក់ទំនងសាកសួរព័ត៌មានអំពីឯកសារនេះ

ការិយាល័យសុវត្ថិភាព
នៃផ្នែកសុវត្ថិភាពអនាម័យ
នៃនាយកដ្ឋានស្តង់ដារការងារ
នៃក្រសួងសុខាភិបាលការងារនិងសុខុមាលភាព